សម្លេងខ្មែរនៅបរទេស

# គួរឱ្យចង់សើច !

## C'est rigolo !

ដោយ លី-ឌៀប ★ ថ្ងៃទី១៩ កក្កដា ២០០៥

នេះជាចំណងជើងនៃអត្ថបទរបស់កាសែត Cambodge Soir ចុះថ្ងៃទី១៩ កក្កដា ដែលសម្ដេចសីហនុបានដកស្រង់មកចុះផ្សាយបន្ត នៅក្នុងទំព័រ<វ៉ែបសាយ> របស់ព្រះអង្គ ។ អត្ថបទមានខ្លឹមសារដូចខាងក្រោមនេះ ៖

«ជាប្រតិកម្មទៅនឹងការវាយប្រហាររបស់ក្រុមជំទាស់ ដែលនិយាយថាគណបក្សរបស់ទ្រង់គ្មានខ្វល់អំពល់អ្វីទាំងអស់អំពីបញ្ហាព្រំដែន <ជាគណបក្សលក់ខ្លួនឲ្យគណបក្សប្រជាជន, លក់ខ្លួនឲ្យយួន>, ទ្រង់រណឫទ្ធិកាលពីថ្ងៃសុក្របានគូសបញ្ជាក់ថា គណបក្សហ៊្វុនស៊ិនប៉ិចកំពុងគាំទ្រយ៉ាងខ្លាំងក្លា នូវគោលជំហររបស់ព្រះមហាក្សត្របិតានរោត្តម-សីហនុ, ប្រធានឧត្តមក្រុមប្រឹក្សាជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

( កកន ៖ នៅក្រោមឃ្លា <ជាគណបក្សលក់ខ្លួនឲ្យគណបក្សប្រជាជន, លក់ខ្លួនឲ្យយួន> សម្ដេចសីហនុគូសបន្ទាត់ពីក្រោម ហើយចារនៅខាងឆ្វេងអត្ថបទថា ៖ គួរឲ្យចង់សើច ! (C'est rigolo!!) ។ ចំណារនេះក៏ធ្វើឲ្យយើងចង់សើចដែរ ពីព្រោះគណបក្សរាជានិយមរបស់ទ្រង់រណឫទ្ធិបានលក់ខ្លួនឲ្យគណបក្សប្រជាជននិងលក់ខ្លួនឲ្យយួន រីចំណែកឯសម្ដេចសីហនុវិញ ទើបប្រកាសក្ដែងៗថា ព្រះអង្គហើយនិងអាយ៉ងយួនហ៊ុន-សែន <តែងតែ, កំពុងតែ និងនៅតែ> ស្រឡាញ់គ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅ ។ «ហើយរហូតដល់ទីបំផុតនៃជីវិតខ្ញុំ ខ្ញុំនឹងនៅតែជាអ្នកគាំទ្រគាត់ ក្នុងឋានៈគាត់ជាមេដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា» (sic) (សូមអានអត្ថបទរបស់សម្ដេចសីហនុ ចុះថ្ងៃទី១៦កក្កដា២០០៥) ។ យើងមិនដឹងថា តើសម្ដេចសីហនុអស់សំណើចពីកូនប្រុស លើកគណបក្សហ៊្វុនស៊ិនប៉ិចទៅលក់ឲ្យគណបក្សប្រជាជននិងយួន ឬមួយក៏ព្រះអង្គអស់សំណើចនឹងខ្លួនព្រះអង្គទេ ?? ។ តែបើតាមមើលទៅ ! ប្រហែលព្រះអង្គហួសព្រះទ័យព្រោះយល់ថា នេះបានចំជាទៅទាំងប៉ីទាំងទ្រមែនតែម្ដងហើយ !! ។ ហេ ! ហេ ! ) ។

ភ្លាមបន្ទាប់ពីការរៀបចំបង្កើតឧត្តមក្រុមប្រឹក្សាជាតិទទួលបន្ទុកកិច្ចការព្រំដែន, គណបក្សហ៊្វុនស៊ិនប៉ិចបានផ្ញើលិខិតមួយច្បាប់ទៅថ្វាយព្រះមហាក្សត្របិតា ដែលផ្ដល់យ៉ាងច្បាស់ អំពីគោលជំហរគណបក្សរបស់ទ្រង់លើចំណុចនេះ, ទ្រង់រណឫទ្ធិរំឭកឡើងវិញ ។ «គណបក្សហ៊្វុនស៊ិនប៉ិចគាំទ្រ ដោយគ្មានលក្ខខណ្ឌចំពោះព្រះរាជនយោបាយរបស់សម្ដេចឪ ក្នុងបញ្ហាព្រំដែន ។ យើងបាននិយាយថា សមាជិកនៃឧត្តមក្រុមប្រឹក្សាជាតិ ត្រូវតែជ្រើសរើសយកផ្ទាំងផែនទីមួយដែលប្រើប្រាស់ជាផ្លូវការ សំរាប់ក្នុងកិច្ចចរចាទាំងអស់ ។ រួចហើយយើងក៏បានស្នើថា ផ្ទាំងផែនទីនោះ គឺត្រូវតែជាផ្ទាំងផែនទីដែលដម្កល់ដោយព្រះមហាក្សត្រនៅអង្គការសហប្រជាជាតិ (កាលពីអំឡុងឆ្នាំ៦០) ។ នាយករដ្ឋមន្ត្រីនិងគណបក្សប្រជាជនយល់ព្រមចំពោះស្ថានភាពនេះ ។ ក្នុងពេលប្រជុំលើកទី១នៃឧត្តមក្រុមប្រឹក្សាជាតិទទួលបន្ទុកកិច្ចការព្រំដែននៅក្រុងប៉េកាំង ផ្ទាំងផែនទីនេះក៏បានទទួលយក ។ ដូច្នេះ ជំហររបស់យើងគឺច្បាស់ណាស់», ទ្រង់រណឫទ្ធិគូសបញ្ជាក់ដោយកំហឹងថាគណបក្សសម-រង្ស៊ីវាយប្រហារទ្រង់អំពីរឿងនេះ ។

អំពីអ្នកខ្លះទាមទារសុំឲ្យលុបចោលសន្ធិសញ្ញាព្រំដែនធ្វើជាមួយយួន កាលអំឡុងឆ្នាំ៨០ រយៈពេលយួនឈ្លានពាន, ទ្រង់រណឫទ្ធិឲ្យយោបល់ផ្ទុយថា «ខ្ញុំបានទូលព្រះមហាក្សត្របិតា ថាសន្ធិសញ្ញាខ្លះប្រឆាំងនឹងប្រយោជន៍របស់ស្រុក ហើយថាយើងសុំទាមទារឲ្យគេលុបចោល ។ ចំពោះសន្ធិសញ្ញាចុះហត្ថលេខាដោយហ៊ុនសែនកាលពីឆ្នាំ១៩៨២, ១៩៨៣ និង១៩៨៥, យើងពុំបានទាមទារឲ្យលុបចោលភ្លាមៗទេ ។ យើងត្រូវធ្វើការចរចាគ្នាជាមុនសិន ជាមួយប្រទេសជិតខាង (ប្រទេសវៀតណាម) ដោយប្រើការយោងទៅលើផ្ទាំងផែនទី ។ បើយើងពុំអាចរកឃើញនូវការចុះសំរុងគ្នាទេ នោះរដ្ឋសភាអាចលុបសន្ធិសញ្ញាទាំងនោះចោល», ទ្រង់រណឫទ្ធិគូសបញ្ជាក់ ។

ត្រឡប់មកបញ្ហាទាក់ទងនឹងអំណាច ដែលគេត្រូវប្រគល់ថ្វាយទៅព្រះមហាក្សត្របិតា ដើម្បីព្រះអង្គចាត់ការបញ្ហាព្រំដែន, ទ្រង់រណឫទ្ធិបានអារកាត់ថា នៅក្នុងតំបន់, ព្រះមហាក្សត្រមានកម្លាំងសីលធម៌យ៉ាងធំធេង គ្រប់គ្រាន់ល្មមជំរុញទៅរកការចរចាជាមួយប្រទេសជិតខាងបាន ។ «តើនរណាទៅមិនស្គាល់ព្រះអង្គនៅក្នុងតំបន់នោះ ? ពេលព្រះអង្គមានព្រះឱង្កា គ្រប់ៗគ្នាស្ដាប់ព្រះអង្គ ! ។ នៅក្រោមលក្ខណៈនេះ, តើចាំបាច់អ្វីថ្វាយអំណាចថែមដល់ព្រះអង្គនោះ ? ។ លើសពីនេះទៅទៀត បើយោងតាមការអនុវត្តន៍ជាអន្តរជាតិ គឺរដ្ឋាភិបាលឯណោះទេដែលជាអ្នកចរចានិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានា ។ សច្ចានុម័តនៃសន្ធិសញ្ញាគឺជាសមត្ថកិច្ចរបស់រដ្ឋសភា ហើយនិងព្រះមហាក្សត្រ ។ តួនាទីក្រុមប្រឹក្សា គឺពិនិត្យមើលនយោបាយព្រំដែនរបស់រដ្ឋាភិបាល ហើយនិងផ្ដល់ការណែនាំទៅរដ្ឋាភិបាល ដើម្បីឲ្យការចរចាប្រព្រឹត្តទៅបានល្អប៉ុណ្ណោះ», ទ្រង់គូសបញ្ជាក់ ។

( កកន ៖ នៅក្រោមនិងនៅចំហៀងខាងស្ដាំនៃអត្ថបទ សម្ដេចសីហនុបានចារយ៉ាងដូច្នេះថា ៖ «យោងតាមរាជក្រឹត្យទាំងពីរថ្មីៗ, សម្ដេចហ៊ុន-សែន ប្រមុខនៃរាជរដ្ឋាភិបាលមានអំណាចសព្វយ៉ាងទាំងអស់ (ហើយដល់ដូច្នេះ ត្រូវតែទទួលការខុសត្រូវទាំងអស់) ចំពោះបញ្ហាព្រំដែនខ្មែរជាមួយប្រទេសជិតខាងទាំង៣ (ថៃ, វៀតណាម និងលាវ) ។ ចំពោះខ្លួនខ្ញុំ, ខ្ញុំគ្មានអំណាចអ្វីឡើយ ហើយដល់ដូច្នេះទៅ ខ្ញុំក៏ពុំត្រូវមានការទទួលខុសត្រូវ ក្នុងបញ្ហាព្រំដែនដ៏សំខាន់និងបញ្ហាបូរណភាពទឹកដីនេះដែរ ។ កុំយកខ្ញុំទៅពាក់ព័ន្ធនឹងបញ្ហាដ៏ធំនេះ» ។ តែតាមយើងដឹង គឺសម្ដេចសីហនុទេតើ តែបានស្ម័គ្រព្រះទ័យមុនគេ សុំធ្វើជាប្រធានឧត្តមក្រុមប្រឹក្សាជាតិទទួលបន្ទុកកិច្ចការព្រំដែន (សូមអានសារព្រះមហាក្សត្រសីហមុនីឆ្លើយតបទៅហ៊ុន-សែន កាលពីថ្ងៃទី២៥មេសា២០០៥) ។ ព្រះអង្គរំភើបព្រះទ័យខ្លាំងណាស់ រហូតដល់ទៅហ៊ានសរសេរសំបុត្រចំហ ទៅកាន់ប្រទេសជិតខាងទាំងបី សុំឲ្យមករួមសហការគ្នាដោះស្រាយបញ្ហាព្រំដែន ។ ព្រះអង្គសន្យាចុះទៅពិនិត្យមើលបង្គោលព្រំដែនមួយគីឡូម៉ែត្រម្ដងៗ ។ ហើយនិងបានអំពាវនាវដល់ប្រជារាស្ត្រ ឲ្យនាំគ្នាក្លែងខ្លួនធ្វើជាទេសចរចារកិច្ច ដើម្បីចុះទៅស៊ើបអង្កេតនៅតាមព្រំដែន យកការណ៍មកថ្វាយព្រះអង្គថែមទៀតផង ។ កិច្ចប្រជុំលើកទី១នៃឧត្តមក្រុមប្រឹក្សាព្រំដែន ក៏បានប្រព្រឹត្តទៅឯរាជវាំងក្រុងប៉េកាំង យ៉ាងគគ្រឹកគគ្រេងផ្អើលគេផ្អើលឯងគ្រប់ទិសទី។ ក៏ប៉ុន្តែក្រោយបន្ទាប់ពីហ្នឹងមក ស្រាប់តែខ្សុយតែម្ដង ។ យើងឮសួរសម្ដេចហែកការណ៍ប្រាប់យើងឲ្យដឹងថា រាជក្រឹត្យដែលព្រះមហាក្សត្របានធ្វើនោះ គឺព្រះអង្គធ្វើតាមការបង្គាប់បញ្ជារបស់ហ៊ុន-សែនទាំងស្រុង ។ ព្រះអង្គមិនមែនប្រាប់យើងតែម្ដងទេ បន្តិចក្រោយមក ព្រះអង្គមានបន្ទូលប្រាប់យើងដដែលទៀតថា ព្រះមហាក្សត្របានធ្វើតាមការបង្គាប់បញ្ជារបស់ហ៊ុន-សែន ឲ្យធ្វើព្រះរាជក្រឹត្យថ្មីមួយទៀត ដើម្បីបង្កើត«អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន» ដែលមានហ៊ុន-សែនជាប្រធាន ។ «អំពើប្រមាថព្រះមហាក្សត្រ»នេះពុំមែនចប់ត្រឹមហ្នឹងទេ សម្ដេចសីហនុបានប្រកាសថា ៖ បើព្រះអង្គគ្មានអំណាច ព្រះអង្គក៏មិនទទួលខុសត្រូវក្នុងបញ្ហាព្រំដែនដែរ ។ រួចហើយព្រះអង្គប្រកាសថា គ្មានកិច្ចប្រជុំក្រុមប្រឹក្សាព្រំដែនទៀតទេ ។ ព្រះអង្គថ្លែងថា ៖ ក្រុមប្រឹក្សាព្រំដែនគឺជារឿងកំប្លុកកំប្លែងដ៏គួរឲ្យអស់សំណើច ។ យើងសូមឆ្ងល់ថា ៖ តើនរណាទៅបង្ខំព្រះអង្គពីដំបូងដៃ ។ តើនរណាទៅ ទៅបង្ខំឲ្យព្រះអង្គឲ្យទទួលខុសត្រូវក្នុងរឿងនេះ ?? ។ តើគួរសម្ដេចសីហនុចង់សើច ឬមួយក៏យើងចង់សើច ? ។ វាគួរឲ្យសោកស្ដាយពន់ពេកណាស់ ដែលបញ្ហាទឹកដីរបស់ខ្មែរ ត្រូវមកបញ្ចប់ត្រឹមរឿងអំណាចនេះ ! ) ។៚